# របាយការណ៍សង្ខេប

## បូកសរុបការងារទេសចរណ៍ ការបូកសរុបផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ ដំណាក់កាលទី១ (២០២០-២០២១) និងឆមាសទី១ ឆ្នាំ២០២២

## និងលើកទិសដៅផែនការស្តារឡើងវិញនូវវិស័យទេសចរណ៍ក្នុងដំណាក់កាលទី២ (ឆមាសទី២ ឆ្នាំ២០២២-២០២៣)

ដោយ ឯកឧត្តម ថិត ចន្ថា
រដ្ឋលេខាធិការប្រចាំការក្រសួងទេសចរណ៍

## សូមគោរពជូន

- ឯកឧត្តមបណ្ឌិត **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ សមាជិក សមាជិការ នៃអង្គសន្និបាត ជាមេត្រី

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងសេចក្តីរីករាយ ដោយបានទទួលការអនុញ្ញាត អាន របាយការណ៍បូកសរុបការងារទេសចរណ៍ ការបូកសរុបផែនការស្តារ និងលើកស្ទួយវិស័យ ទេសចរណ៍កម្ពុជាក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ ដំណាក់កាលទី១ (២០២០-២០២១) និងឆមាស ទី១ ឆ្នាំ២០២២ និងលើកទិសដៅផែនការស្តារឡើងវិញនូវវិស័យទេសចរណ៍ក្នុងដំណាក់កាល ទី២ (ឆមាសទី២ ឆ្នាំ២០២២-២០២៣)។

ដើម្បីសម្រួលដល់ការស្តាប់ និងអាស្រ័យដោយពេលវេលា ខ្ញុំសូមអានជូននូវចំនុច គោលសំខាន់ៗ នៃរបាយការណ៍ អមដោយបទបង្ហាញរូបភាពបន្ថែមជាមួយ ។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី វិស័យទេសចរណ៍កម្ពុជា គឺជាទេសចរណ៍ វប្បធម៌ និងធម្មជាតិ ។

ទីផ្សារដែលមកពីបណ្ដាប្រទេសនៃ**តំបន់អឺរ៉ុប និងអាមេរិក** ដែលភាគច្រើនជាការធ្វើដំណើរផ្ទៃក្នុងតំបន់និងការធ្វើដំណើរទៅមករវាងអាមេរិកនិងអឺរ៉ុប។ ដោយឡែក ប្រទេសជាគោលដៅទេសចរណ៍ដែលងើបឡើងវិញលឿនជាងគេក្នុងឆ្នាំ២០២២នេះ**គឺគោលដៅឆ្នេរសមុទ្រ ឬកោះ**។

នៅឆ្នាំ២០២២ នេះ វិស័យទេសចរណ៍សកលលោករំពឹងនឹងមានភាពល្អប្រសើរ ដោយសារការចាប់ផ្ដើមកម្រើកឡើងវិញនៃចរន្តនៃការធ្វើដំណើររបស់ភ្ញៀវទេសចរអន្តរជាតិ ដែលទទួលបានឥទ្ធិពលវិជ្ជមានពីការបន្ធូរបន្ថយការរឹតត្បិត និងការដករបាំងដែលជាលក្ខខណ្ឌនានាលើការធ្វើដំណើរ ជាមួយការកើនឡើងក្នុងការធ្វើដំណើរជួបជុំគ្រួសារការធ្វើធុរកិច្ច និងការកម្សាន្តក្រោយពីខកខានអស់មួយរយៈ។ តាមការព្យាករណ៍របស់អង្គការទេសចរណ៍ពិភពលោក ចំនួនទេសចរថយចុះក្នុងចន្លោះពី -៣០%- ទៅ -៤៥% បើធៀបនឹងចំនួនទេសចរអន្តរជាតិនៅក្នុងឆ្នាំ២០១៩ ដោយសារវិស័យទេសចរណ៍សាកលលោកកំពុងទទួលរងការគំរាមកំហែងនានា ដូចជាការវិវត្តជាបន្តបន្ទាប់នៃ ជំងឺកូវីដ-១៩បម្លែងថ្មី និងជំងឺឆ្លងផ្សេងៗទៀត, វិបត្តិនៅអ៊ុយក្រែន ដែលធ្វើឱ្យមានការកើនឡើងនូវអតិផរណាជារួម, ការកើនឡើងខ្លាំងនៃថ្លៃប្រេងនិងការថមថយអំណាចទិញរបស់ភ្ញៀវ, ល្បឿនខុសៗគ្នានៃការបន្ធូរបន្ថយការរឹតត្បិតការធ្វើដំណើរ និងរបាំងនានារបស់ប្រទេសនីមួយៗ ជាដើម។

## ២.សភាពការណ៍ទេសចរណ៍ និងចក្ខុវិស័យនៃវិស័យទេសចរណ៍កម្ពុជា

### ២.១. សភាពការណ៍ទេសចរណ៍កម្ពុជា

ទេសចរអន្តរជាតិមកទស្សនាកម្ពុជាក្នុងឆ្នាំ២០២១មានចំនួនជាង**១៩នាក់** ថយចុះ **៨៥%** ធៀបនឹងឆ្នាំ ២០២០ ក្នុងនោះ:

- ផ្លូវអាកាស: ថយចុះ **៨៦.៨%**
- ផ្លូវគោក: ថយចុះ **៨០.៦%**
- ផ្លូវទឹក: ថយចុះ **៩៩.៦%**

*** អំពីចំនួនទេសចរអន្តរជាតិផ្ទៃក្នុង**

ក្នុងឆ្នាំ២០២១ ទេសចរជាតិ ដែលបានធ្វើដំណើរកម្សាន្តតាមបណ្ដារមណីដ្ឋាននានាទូទាំងប្រទេសមានប្រមាណ **៤,៧លាននាក់** ថយចុះ**៣៥.៥%** និងទេសចរបរទេសប្រមាណ **២៨ម៉ឺននាក់** ថយចុះ **៨៤.៦%** ធៀបនឹងឆ្នាំ២០២០។

*** អំពីចំនួនទេសចរជាតិចេញទៅក្រៅប្រទេស** (Cambodia Outbound Tourists)

ឆ្នាំ២០២១ ទេសចរជាតិចេញទៅក្រៅប្រទេសមានចំនួន **១៨ម៉ឺននាក់** ថយចុះ៨៦.៦% ធៀបនឹងឆ្នាំ ២០២០ ។

សម្រាប់**ឆមាសទី១ ឆ្នាំ២០២២**នេះ ទេសចរអន្តរជាតិមកទស្សនាកម្ពុជាមានចំនួនប្រមាណ**៥០ម៉ឺននាក់** កើនឡើង ៣៩៤.១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១ ក្នុងនោះ :

- ផ្លូវអាកាស: **២៤ម៉ឺននាក់** កើនឡើង ៤២០,៣%
- ផ្លូវគោក: **២៦ម៉ឺននាក់** កើនឡើង ៣៦៤,៤%
- ផ្លូវទឹក: **៥៣ាន់នាក់** កើនឡើង ២៣០,៤00%

* **ចំនួនទេសចរផ្ទៃក្នុង** (Internal Tourist)

សម្រាប់**ឆមាសទី១ ឆ្នាំ២០២២**នេះ ទេសចរជាតិ ដែលបានធ្វើដំណើរកម្សាន្តតាមបណ្តារមណីយដ្ឋាននានាទូទាំងប្រទេសមានចំនួន **៦,៣លាននាក់** កើនឡើង **២១៩.៣%** និងទេសចរបរទេសចំនួន**៦៨ម៉ឺននាក់** កើនឡើង **៣៨០.៣%** ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១។

## ២.២. ចក្ខុវិស័យនៃវិស័យទេសចរណ៍កម្ពុជា

ចក្ខុវិស័យនៃវិស័យទេសចរណ៍កម្ពុជាផ្តោតសំខាន់ការរៀបចំស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ ដោយការងើបឡើងវិញនៃវិស័យទេសចរណ៍កម្ពុជានឹងផ្អែកតាម**សេណារីយ៉ូចំនួន ០២ គឺ៖**

- ករណីសភាពការណ៍ពិភពលោក និងតំបន់មានសភាពប្រសើរឡើងតាមរយៈការសម្រួលការធ្វើដំណើរ (ពិសេសការដកចេញនូវគោលនយោបាយគ្មានកូវីដ-១៩ - Zero-COVID Policy) របស់ប្រទេសចិននៅក្នុងឆ្នាំ២០២៣ខាងមុខនេះ) វិស័យទេសចរណ៍កម្ពុជារំពឹងថាអាចនឹងឈានទៅងើបឡើងវិញ និងទទួលបានចំនួនទេសចរអន្តរជាតិប្រមាណ**៧លាននាក់នៅឆ្នាំ២០២៦**។

- ផ្ទុយមកវិញករណីសភាពការណ៍ពិភពលោក និងតំបន់មិនទាន់មានសភាពល្អប្រសើរសម្រាប់ការធ្វើ ដំណើរ (ពិសេស ការដកចេញនូវគោលនយោបាយគ្មានកូវីដ-១៩ - Zero-COVID Policy) របស់ប្រទេស ចិននៅក្រោយឆ្នាំ២០២៣) វិស័យទេសចរណ៍កម្ពុជារំពឹងថាអាចនឹងឈានទៅងើបឡើងវិញ និងទទួលបានចំនួនទេសចរអន្តរជាតិប្រមាណ **៧លាននាក់នៅឆ្នាំ២០២៧**។

ដោយឡែក សម្រាប់ការព្យាករណ៍**ឆ្នាំ២០២២នេះ** កម្ពុជានឹងអាចទទួលទេសចរអន្តរជាតិប្រមាណ**៨០ម៉ឺន-១លាននាក់** និងទេសចរផ្ទៃក្នុងប្រមាណ**១០-១១លាននាក់**។

## III. លទ្ធផលអនុវត្តការងារទេសចរណ៍ឆ្នាំ២០២០-២០២១ និងឆមាសទី១ ឆ្នាំ២០២២

### ១.លទ្ធផលអនុវត្តគោលដៅយុទ្ធសាស្ត្រទី១៖ ជំនួយផ្នែកសេដ្ឋកិច្ចចំពោះវិស័យឯកជន និងការងារ

#### ១.១. ការអនុវត្តវិធានការគាំទ្រសេដ្ឋកិច្ច សង្គម និងការងារក្នុងវិស័យទេសចរណ៍

ដើម្បីជំរុញ និងទ្រទ្រង់ផ្នែកឯកជនក្នុងវិស័យទេសចរណ៍ក្នុងដំណាក់កាលវិបត្តិជំងឺកូវីដ-១៩ ក្នុងគោលដៅ រក្សាតុល្យភាពនៃសេដ្ឋកិច្ចនិងការងារ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការដើម្បីបន្តគ្រប់គ្រងផលប៉ះពាល់លើវិស័យសំខាន់ៗនៃសេដ្ឋកិច្ចជាតិនៅក្នុងបរិការណ៍នៃវិបត្តិ និងការស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩បានចំនួន**១០ជុំ** រួចមកហើយ។ វិធានការទាំងនេះបានចាប់ផ្តើមអនុវត្តតាំងពីខែ**កុម្ភៈ ឆ្នាំ២០២០** រហូតដល់**ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** ដែលផ្តោតលើជំនួយសេដ្ឋកិច្ច-សង្គម ដូចខាងក្រោម៖

- ផ្តល់ប្រាក់ឧបត្ថម្ភ**៤០ដុល្លារ**អាមេរិកក្នុងមួយខែ ជូនកម្មករនិយោជិត០១នាក់ ដែលព្យួរការងារក្នុង វិស័យទេសចរណ៍ដូចជា៖ សណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន និងភ្នាក់ងារទេសចរណ៍។ **គិតត្រឹមថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០២២** រាជរដ្ឋាភិបាលបានផ្តល់ប្រាក់ឧបត្ថម្ភ៤០ដុល្លារអាមេរិកក្នុងមួយ ខែជូនកម្មករនិយោជិត ដែលបានព្យួរកិច្ចសន្យាការងារបាន**ចំនួន២៣,០១០នាក់** ដោយចំណាយថវិកាជាតិចំនួន **៣៥,៨០៩,៤២៩,៦០០ រៀល** ប្រហែលនឹង**៨,៩៥លានដុល្លារ អាមេរិក**។
- លើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទចំពោះសណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន និងក្រុមហ៊ុន ភ្នាក់ងារទេសចរណ៍ និងមានសកម្មភាព អាជីវកម្មនៅក្នុងរាជធានីភ្នំពេញ, ខេត្តសៀមរាប, ខេត្តព្រះសីហនុ, ខេត្តកែប, ខេត្តកំពត, ក្រុងបាវិត និងក្រុងប៉ោយប៉ែត។
- លើកលែងការបង់ថ្លៃបន្តអាជ្ញាបណ្ណទេសចរណ៍គ្រប់ប្រភេទនៅក្នុងវិស័យទេសចរណ៍ សម្រាប់ឆ្នាំ ២០២១។
- ពន្យារការចាប់ផ្តើមអនុវត្តរបបសន្តិសុខសង្គមផ្នែកសោធនរហូតដល់ខែធ្នូឆ្នាំ២០២១។ ការពន្យាពេល នេះនឹងត្រូវផ្អែកលើការវាយតម្លៃជាបន្តបន្ទាប់នូវស្ថានភាពសង្គម-សេដ្ឋកិច្ចជាក់ស្តែង។

- លើកលែងការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពនៃបេឡាជាតិសន្តិសុខសង្គមក្នុងអំឡុងពេលព្យួរអាជីវកម្ម ឬផ្អាកដំណើរការអាជីវកម្ម។

- លើកលែងការបង់ពន្ធប៉ាតង់ និងពន្ធលើតែមប្រើសារពើពន្ធ (ពន្ធលើស្លាកយីហោ) ចំពោះក្រុមហ៊ុន ភ្នាក់ងារទេសចរណ៍ និងប្រតិបត្តិករក្នុងវិស័យទេសចរណ៍ដទៃទៀត។

- រក្សាថ្លៃសំបុត្រចូលទស្សនាតំបន់អង្គរឱ្យនៅដដែល ប៉ុន្តែបន្ថែមចំនួនថ្ងៃសម្រាប់ប្រភេទសំបុត្រនីមួយៗសំបុត្រសម្រាប់១ថ្ងៃអាចចូលមើលបាន២ថ្ងៃ សំបុត្រសម្រាប់រយៈពេល៣ថ្ងៃអាចចូលមើល បាន៥ថ្ងៃ និងសំបុត្រសម្រាប់៧ថ្ងៃអាចចូលមើលបាន១០ថ្ងៃ។

ដោយឡែកសម្រាប់**ឆមាសទី១ ឆ្នាំ២០២២** រាជរដ្ឋាភិបាលបានបន្តដាក់ចេញវិធានការគោលនយោបាយ គន្លឹះសម្រាប់វិស័យទេសចរណ៍ឆ្នាំ២០២២ ដើម្បីជំរុញការងើបឡើងវិញនៃវិស័យទេសចរណ៍ រួមមានៈ

- បន្តលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទចំពោះសណ្ឋាគារ, ផ្ទះសំណាក់,ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ។ ករណីមានបំណុលសល់ពីមុនវិបត្តិនៃ ជំងឺកូវីដ-១៩ ចំពោះប្រតិបត្តិករក្នុងវិស័យទេសចរណ៍សម្រាប់ខេត្តដទៃទៀត ត្រូវពន្យាពេលការចុះធ្វើសវនកម្មនៅ ក្នុងឆ្នាំ២០២១។

- បន្តលើកលែងការបង់ពន្ធប៉ាតង់ចំពោះក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ និងប្រតិបត្តិករក្នុងវិស័យទេសចរណ៍ដទៃទៀតសម្រាប់ឆ្នាំ២០២២។

- លើកលែងការបង់កម្រៃបន្តអាជ្ញាបណ្ណទេសចរណ៍គ្រប់ប្រភេទសម្រាប់ឆ្នាំ២០២២ ចំពោះអាជ្ញាបណ្ណទេសចរណ៍ដែលស្ថិតក្នុងសុពលភាព។

- បន្តសុពលភាពនៃការអនុវត្តសេចក្តីជូនដំណឹងស្តីពីការអនុវត្តគោលនយោបាយលើកទឹកចិត្តនៃការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គររហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

## ១.២. ការអនុវត្តវិធានការគាំទ្រហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យមក្នុងវិស័យទេសចរណ៍

ក្រៅពីយន្តការជំនួយសេដ្ឋកិច្ច-សង្គម និងការងារ រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីទ្រទ្រង់ក្រោមទម្រង់ជាសហហិរញ្ញប្បទានមួយចំនួន ដោយគិតត្រឹមថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ រាជរដ្ឋាភិបាលបានធ្វើបដិភាគកម្មវិធីសហហិរញ្ញប្បទានក្នុងទំហំទឹកប្រាក់**១៧០លានដុល្លារ** ដែលផ្តល់អាទិភាពលើវិស័យសំខាន់ៗមួយចំនួនដូចជា **កសិកម្ម, កសិ-ឧស្សាហកម្ម, ការកែច្នៃម្ហូបអាហារ, កម្មន្តសាល, គ្រឿងបង្គុំ និងទេសចរណ៍** ជាដើម ។ កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ថ្មីៗនេះ រាជរដ្ឋាភិបាលបានដាក់បញ្ចេញគម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើនវិស័យទេសចរណ៍ក្នុងទំហំទឹកប្រាក់**១៥០លានដុល្លារ**អាមេរិក ក្នុងនោះរាជរដ្ឋាភិបាលមានបដិភាគចំនួន**៧៥លានដុល្លារអាមេរិក** និងគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមមាន បដិភាគ**៧៥លានដុល្លារអាមេរិក**។ គម្រោងសហហិរញ្ញប្បទាននេះនឹងផ្តល់លទ្ធផលដល់អាជីវកម្មទេសចរណ៍ ទទួលបានកម្ចីពីគ្រឹះស្ថាហិរញ្ញវត្ថុចូលរួមក្នុងអត្រាការប្រាក់សម្បទាន និងទំហំទឹកប្រាក់ច្រើន។ លើសពីនេះដើម្បីសម្រួលដល់អាជីវកម្មទេសចរណ៍ដែលកង្វះទ្រព្យបញ្ចាំសម្រាប់ធានាកម្ចី រាជរដ្ឋាភិបាលតាមរយៈសាជីវកម្មធានាឥណទានកម្ពុជាក៏បានដាក់ចេញនូវកម្មវិធីធានាឥណទានកម្ពុជាសម្រាប់វិស័យទេសចរណ៍ ដើម្បីបំពេញបន្ថែមគម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើនវិស័យទេសចរណ៍កម្ពុជា។

### ១.៣. ការផ្តល់កិច្ចគាំពារសម្រាប់អាជីវកម្មទេសចរណ៍ខ្នាតតូច និងមធ្យម

ស្របតាមការវិវត្តន៍នៃបរិបទសង្គម និងដើម្បីទ្រទ្រង់ដំណើរការអាជីវកម្មក្នុងដំណាក់កាលកូវីដ-១៩ ក្រសួងទេសចរណ៍បានដាក់ចេញកម្មវិធីគាំពារអាជីវកម្មទេសចរណ៍ជាច្រើនរួមមាន៖

- បានផ្ទេរភារកិច្ចនៃគ្រប់គ្រងអាជ្ញាបណ្ណទេសចរណ៍សម្រាប់អាជីវកម្មដឹកជញ្ជូនទេសចរណ៍ទាំងផ្លូវគោក និងទឹកជូនក្រសួងសាធារណការនិងដឹកជញ្ជូន ។
- បានសម្រេចការសម្រួលការផ្តល់អាជ្ញាបណ្ណទេសចរណ៍ច្រើនប្រភេទ ចំពោះបុគ្គលស្នើសុំតែម្នាក់ ចេញពីទីតាំងតែមួយតាមរយៈថ្នាលអនឡាញ CamDx។
- បានសម្រេចកែសម្រួលបទដ្ឋានគតិយុត្តស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដោយបានកាត់បន្ថយលក្ខខណ្ឌតម្រូវមួយចំនួន ដើម្បីសម្រួលដល់ការស្នើសុំធ្វើធុរកិច្ចក្នុងវិស័យទេសចរណ៍ ក្នុងនោះរួម មានសេវាកម្មការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍, សណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍, ភោជនីយដ្ឋាននិងអាហារដ្ឋានទេសចរណ៍ និងម៉ាស្សា ជាដើម។

- បានរៀបចំសិក្ខាសាលាស្រង់មតិ និងប្រជុំពិភាក្សាជាមួយម្ចាស់អាជីវកម្មទេសចរណ៍ ដើម្បីប្រមូលធាតុចូល រៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច-ហិរញ្ញវត្ថុមកលើវិស័យទេសចរណ៍កម្ពុជា និងដាក់ចេញវិធានការសេដ្ឋកិច្ច-សង្គម និងការងារឱ្យបានសមស្រប។

- ក្រសួងទេសចរណ៍បានចុះអនុស្សរណៈយោគយល់ជាមួយ សហភាពសហព័ន្ធកម្ពុជា និងប្រកាសបើកយុទ្ធនាការ **"អក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍២០២១-២០២៥"** ដោយបច្ចុប្បន្នបានបណ្តុះបណ្តាលវគ្គគ្រូបង្គោល និងវគ្គបណ្តុះបណ្តាលខ្លីៗលើផ្នែកអក្ខរកម្មឌីជីថលដល់មន្ត្រីក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ សមាជិក សមាជិកា ស.ស.យ.ក និងនិស្សិតបានជាច្រើនវគ្គបាន**ប្រមាណជាង១,៥០០នាក់**។

ទន្ទឹមនឹងនោះ ក្រសួងទេសចរណ៍ក៏បានសម្រេចការរៀបចំប្រព័ន្ធគ្រប់គ្រងតាមបែបឌីជីថល និងបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ រួមមាន៖

- ប្រព័ន្ធចុះបញ្ជីទទួលស្គាល់អាជីវកម្មទេសចរណ៍ដែលទទួលបានឡាបិលសុវត្ថិភាពទេសចរណ៍
- ប្រព័ន្ធគ្រប់គ្រងកញ្ចប់ទស្សនកិច្ចទេសចរណ៍ចាក់វ៉ាក់សាំងកូវីដ-១៩។
- ប្រព័ន្ធគ្រប់គ្រងទេសចរណ៍ក្នុងស្រុក។
- ប្រព័ន្ធគ្រប់គ្រងសមត្ថភាពផ្ទុកទេសចរ។

### ១.៤. ជំរុញការបណ្តុះបណ្តាលចំណេះដឹងថ្មី និងបង្កើនចំណេះដឹងបន្ថែម

ក្រសួងទេសចរណ៍បានអនុវត្ត និងសម្រេចកម្មវិធីការងារបណ្តុះបណ្តាលដោយផ្ទាល់ និងតាមរយៈប្រព័ន្ធអនឡាញ ដូចខាងក្រោម៖

- បានរៀបចំវគ្គបណ្តុះបណ្តាលតាមអនឡាញបានចំនួន**១០៦ថ្នាក់**លើមុខវិជ្ជា ចំនួន**៤៣មុខ**ដែលមានសិក្ខាកាមចុះឈ្មោះសរុបចំនួន**១,២៤១នាក់** និងសិក្ខាកាមតាមថ្នាក់សរុបចំនួន**៥២,៧៤១នាក់** ដោយគ្រប់ដណ្តប់លើសេវាកម្មទេសចរណ៍ចំនួន០៩មុខ។

- រៀបចំវគ្គបំប៉ុនសមត្ថភាពមគ្គុទ្ទេសក៍ទេសចរណ៍, ស្ត្រីក្នុងសហគមន៍, គ្រូបង្គោលសហគ្រិនភាពក្នុងវិស័យទេសចរណ៍, មន្ទីរទេសចរណ៍ និងបុគ្គលិកក្នុងឧស្សាហកម្មទេសចរណ៍លើជំនាញផ្សេងៗ ដោយចូលរួមដោយផ្ទាល់ (In Class Training ) បានជាង**២,០០០នាក់**។

- ក្រោមកិច្ចសហការជាមួយជាមួយអង្គការ SwissContact, គណៈកម្មការគ្រប់គ្រងគម្រោង ហូកា បានបណ្តុះបណ្តាលគ្រូបង្គោលចំនួន**១០៧នាក់** លើជំនាញការិយាល័យជួរមុខ គេហកិច្ច និងសេវាកម្មម្ហូបអាហារនិងភេសជ្ជៈ, អ្នកជំនាញកម្រិតទាប និងបុគ្គលិកកំពុងបម្រើការងារចំនួន**១០០នាក់**។

- បានសហការរៀបចំការវាយតម្លៃលើការសិក្សាពីមុន (Recognition of Prior Learning-RPL) ដល់អ្នកជំនាញទេសចរណ៍សេវាកម្មសណ្ឋាគារបានចំនួនប្រមាណ **២,២០០នាក់** ។

- កំពុងសាងសង់សាលាជាតិវិជ្ជាជីវៈទេសចរណ៍ (VST) ចំនួន០២ទីតាំង **១.**នៅទីក្រុងភ្នំពេញ **២.**នៅខេត្តព្រះសីហនុ។

- បានដាក់ឱ្យអនុវត្តកម្មវិធីសិក្សាអាស៊ាន (៣២មុខជំនាញ) តាមសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ និងសាកលវិទ្យាល័យ**ចំនួន២០** ។

- បានបញ្ជូនអ្នកជំនាញកម្ពុជាចំនួន៣០រូប (គ្រូបង្គោល១៥នាក់ និងអ្នកវាយតម្លៃបង្គោល១៥នាក់) ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលអាស៊ានលើផ្នែកការិយាល័យជួរមុខ,ផ្នែក គេហកិច្ច, ផ្នែកសេវាកម្មម្ហូបអាហារនិងភេសជ្ជៈ, ផ្នែកផលិតកម្មម្ហូបអាហារ និងផ្នែកការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍។

- បានបណ្តុះបណ្តាលគ្រូបង្គោលជាតិ និងអ្នកវាយតម្លៃបង្គោលជាតិនៃសេវាកម្មសណ្ឋាគារ និងសេវាកម្ម ធ្វើដំណើរចំនួន**៧៣០នាក់** ។

## ២. លទ្ធផលអនុវត្តគោលដៅយុទ្ធសាស្ត្រទី២៖ ជំរុញទេសចរណ៍ក្នុងស្រុក និងការទទួលភ្ញៀវទេសចរទេសចរអន្តរជាតិ

ដើម្បីជំរុញចលនាទេសចរណ៍ផ្ទៃក្នុងនិងសម្រួលដល់សកម្មភាពដំណើរកម្សាន្តប្រកបដោយសុវត្ថិភាព និងទទួលភ្ញៀវទេសចរអន្តរជាតិ រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រចំនួន០២ រួមមាន៖

- វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង (២០២១-២០២៣)
- ផែនការយុទ្ធសាស្ត្រស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង។

### ២.១. វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង (២០២១-២០២៣)

គិតត្រឹមខែមិថុនា ឆ្នាំ២០២២ ការជំរុញចលនាទេសចរណ៍ផ្ទៃក្នុងសម្រេចបានប្រមាណ **៥៨%**នៃការព្យាករណ៍១១លាននាក់សម្រាប់ឆ្នាំ២០២២។ បច្ចុប្បន្ន ទេសចរផ្ទៃក្នុងជាមធ្យមប្រមាណ **៣០ម៉ឺននាក់** បានធ្វើដំណើរកម្សាន្តក្នុងប្រទេសជារៀងរាល់សប្តាហ៍។ ក្រសួងទេសចរណ៍បានអនុវត្តសកម្មភាពជាច្រើនស្របតាមគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង រួមមាន៖

- វិធានសុវត្ថិភាពទេសចរណ៍និង**នីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា** (SOP) **តាមគន្លងប្រក្រតីភាពថ្មី** លើសេវាកម្មទេសចរណ៍ចំនួន**១៤សេវា** ដោយគិតត្រឹម**ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២** បានផ្តល់ឡាបិលវិធានសុវត្ថិភាពទេសចរណ៍ទូទាំងប្រទេសបាន **១,៩៨៥ទីតាំង** ដែលកំពុងដំណើរការដើម្បីបង្កើតទំនុកចិត្ត **"កម្ពុជា៖ ជាគោលដៅសុវត្ថិភាព និងបៃតង"**។

- បានជំរុញ និងលើកទឹកចិត្តការដាក់ចេញនូវកម្មវិធីកញ្ចប់ទស្សនកិច្ចថ្លៃសមរម្យទៅកាន់គោលដៅនានារបស់កម្ពុជាដោយភ្ជាប់កម្មវិធីលើកទឹកចិត្តសម្រាប់អាជីវកម្មដែលរួមចូលបញ្ចុះថ្លៃលើសេវាកម្មរបស់ខ្លួន និងការសិក្សារៀបចំបណ្ណទេសចរណ៍កម្ពុជា (Cambodia Pass)។

- បានពង្រឹងយន្តការផ្តល់ព័ត៌មានអំពីគោលដៅទេសចរណ៍ក្នុងស្រុកថ្មីៗ តាមរយៈមណ្ឌលព័ត៌មានទេសចរណ៍រាជធានីខេត្ត, ការផលិតឯកសារផ្សព្វផ្សាយក្នុងស្រុកជាអាទិ៍ សៀវភៅមគ្គុទ្ទេសក៍ពីគោលដៅទេសចរណ៍, សៀវភៅបញ្ជីសារពើភណ្ឌមុខម្ហូបប្រចាំរាជធានីខេត្ត, សៀវភៅ**អាហារតាមផ្លូវកម្ពុជា** (Cambodia Street Foods) ជាដើម និងកម្មវិធីប្រកួតប្រជែងរូបថត **"ទេសចរម្នាក់ រូបថតមួយសន្លឹក"** ដើម្បីផ្សព្វផ្សាយយុទ្ធនាការ **"ទស្សនាស្រុកយើង៖ ស្រឡាញ់ជាតិត្រូវស្គាល់ទឹកដី"**។

- បានផលិតស្ប៉តផ្សព្វផ្សាយសក្តានុពលគោលដៅទេសចរណ៍ជាច្រើនជាង៥០គោលដៅ និងធ្វើការ ផ្សព្វផ្សាយតាមគ្រប់ប្រព័ន្ធផ្សព្វផ្សាយសង្គម រួមមាន Facebook, Channel Telegram, Instagram និង Youtube ជាដើម។

## ២.២. ផែនការយុទ្ធសាស្ត្រស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង

គិតត្រឹមខែមិថុនា ឆ្នាំ២០២២ ទេសចរអន្តរជាតិមកទស្សនាកម្ពុជាមានជាង**៥០ម៉ឺននាក់** សម្រេចបាន **៥០%** នៃការព្យាករណ៍១លាននាក់សម្រាប់ឆ្នាំ២០២២។ ក្រសួងទេសចរណ៍បានអនុវត្តសកម្មភាពទាំងការតាំងពិពរណ៍ ផ្សព្វផ្សាយដោយផ្ទាល់និងតាមប្រព័ន្ធអនឡាញ, ការធ្វើ

Roadsho, ការផលិតជាសៀវភៅផ្សព្វផ្សាយ ការផ្សព្វផ្សាយតាមបណ្តាញ ទូរទស្សន៍អន្តរជាតិ តាមស្ថានតំណាងរបស់កម្ពុជាជាច្រើន រួមមានៈ

- បានចូលរួមការតាំងពិព័រណ៍ផ្សព្វផ្សាយសម្រាប់ទីផ្សារចិនបានជាច្រើនលើកតាមប្រព័ន្ធអនឡាញ, ទីផ្សារ រុស្ស៊ី, ទីផ្សារហ្វីលីពីន អារ៉ាប់រួម និងឥណ្ឌូនេស៊ី ជាដើម។

- បានផលិតសៀវភៅផ្សព្វផ្សាយជាច្រើនភាសា ។

- បានរៀបចំទស្សនកិច្ចសិក្សាស្វែងយល់គោលដៅទេសចរណ៍កម្ពុជាជូនប្រតិភូអន្តរជាតិ (Farm Trip) ឆ្នាំ២០២១ និង២០២២ បានជាច្រើនលើក ។

- បានជំរុញការផ្សព្វផ្សាយទេសចរណ៍អន្តរជាតិតាមតាមរយៈយន្តការស្ថានតំណាងទេសចរណ៍ ក្នុងនោះ ក្រសួងទេសចរណ៍មានអនុព័ន្ធទេសចរណ៍អមស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងប៉េកាំងចំនួន០១, ស្ថានតំណាងទេសចរណ៍ចំនួន១៥ និងទីប្រឹក្សាចំនួន០៧។

- បានធ្វើការផ្សព្វផ្សាយព័ត៌មានជាប្រចាំដល់ភ្ញៀវជាតិ និងអន្តរជាតិតាមរយៈប្រព័ន្ធបច្ចេកវិទ្យា ។

- បច្ចុប្បន្ន ក្រសួងទេសចរណ៍បានសហការជាមួយដៃគូសារព័ត៌មានអន្តរជាតិ ដើម្បីផ្សព្វផ្សាយពីកម្ពុជាៈ ជាគោលដៅទេសចរណ៍សុវត្ថិភាព រួមមាន BBC, CNN, TRAVEL WEEKLY ASIA. TTG MEDIA, ។ល។

- បានភ្ជាប់កិច្ចសហការជាមួយក្រុមហ៊ុន East Colibri Co.,Ltd (Sigur Travel) និងក្រុមហ៊ុន Asia Planet សម្រាប់ការផ្សព្វផ្សាយពីកម្ពុជាលើគេហទំព័ររបស់ក្រុមហ៊ុន ដោយធ្វើការផុសជារៀងរាល់ ១៥ថ្ងៃម្តង។

- ក្រសួងទេសចរណ៍ សហការជាមួយទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD) និងក្រុមហ៊ុនកុងស៊ុលតង់ បាននិងកំពុងរៀបចំសកម្មភាពស្តីពី "ការត្រួតពិនិត្យឡើងវិញនូវ និងការរៀបចំយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍កម្ពុជាតាមប្រព័ន្ធឌីជីថលទៅកាន់ទីផ្សារទេសចរណ៍អន្តរជាតិ"។

## ២.៣. ការអភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសម្រាប់ទទួលភ្ញៀវជាតិនិងអន្តរជាតិ

ដើម្បីរៀបចំលក្ខណៈសម្បត្តិឱ្យបានបានគ្រប់គ្រាន់សម្រាប់ទទួលភ្ញៀវទេសចរជាតិ និងអន្តរជាតិ រាជរដ្ឋាភិបាលបានសម្រេចការអភិវឌ្ឍន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជាច្រើនៈ

- ការកសាងផ្លូវចំនួន៣៤ខ្សែ ប្រវែង៨៤គីឡូម៉ែត្រ អាងប្រព្រឹត្តិកម្មទឹកកខ្វក់ចំនួន០៣ និងសមិទ្ធផលនានាក្នុងក្រុងព្រះសីហនុ ដើម្បីប្រែក្លាយមុខមាត់ថ្មីនៃខេត្តព្រះសីហនុ ជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង។
- គម្រោងកែលម្អផ្លូវ៣៨ខ្សែ ប្រវែង១០៦.៤២គីឡូម៉ែត្រ នៅក្រុងសៀមរាប។
- បានសម្រេចការសាងសង់៩៨% លើគម្រោងកំពង់ផែទេសចរណ៍អន្តរជាតិខេត្តកំពត ដែលជាគម្រោងហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សម្រាប់អនុតំបន់ទន្លេមេគង្គ និងមានសមត្ថភាពអាចទទួលទេសចរប្រមាណ១លាននាក់ និងទទួលកប៉ាល់ចុះចតចំណុះពី៣០០-៤០០នាក់។
- សម្រេចការសាងសង់គម្រោងច្រកទ្វារអន្តរជាតិប៉ោយប៉ែតថ្មីដែលបានសម្ពោធដាក់ឱ្យប្រើប្រាស់នៅក្នុងខែមីនា ឆ្នាំ២០២២។

## ២.៤. ការងារសន្តិសុខនិងសុវត្ថិភាពទេសចរណ៍ និងការងារសម្រួលការធ្វើ ដំណើរ និងដឹកជញ្ជូនភ្ញៀវ ទេសចរនិងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស

- បានដាក់ចេញនូវនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមាសម្រាប់ដំណើរទេសចរណ៍បើកបរដោយខ្លួនឯងតាមផ្លូវគោក។
- បានប្រជុំក្រុមការងារចំពោះកិច្ចដើម្បីដោះស្រាយបញ្ហាប្រឈមនៅច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម (ច្រកទន្លេព្រៃវល្លិ៍ ខេត្តស្វាយរៀង)។
- បានដឹកនាំ ត្រួតពិនិត្យដំណើរការចេញ-ចូលរបស់ទេសចរអន្តរជាតិ, ការសម្រួលការធ្វើដំណើរ តាមច្រកទ្វារ និងបញ្ហាប្រឈមនានានៅព្រលានយន្តហោះអន្តរជាតិខេត្តព្រះសីហនុ និងខេត្តសៀមរាប និងត្រៀមទទួលវេទិកាទេសចរណ៍អាស៊ានទី៤០។
- បានរៀបចំ ដោះស្រាយបញ្ហាប្រឈម និងសំណូមពរមួយចំនួនរបស់ផ្នែកឯកជនក្នុងវិស័យទេសចរណ៍ ពាក់ព័ន្ធនឹងតំបន់ច្រកទ្វារអន្តរជាតិប៉ោយប៉ែត (នៅរាជធានីភ្នំពេញ និង ខេត្តបន្ទាយមានជ័យ) ។
- បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន០២វគ្គស្តីពី **"បដិសណ្ឋារកិច្ចល្អ ទេសចរមានសុវត្ថិភាព"** ជូនមន្ត្រី សមត្ថកិច្ចប្រចាំការច្រកទ្វារព្រំដែនអន្តរជាតិជាបន្តបន្ទាប់។

## ២.៥. ការភ្ជាប់ទំនាក់ទំនង និងកិច្ចសហការតំបន់ និងអន្តរជាតិ

- សហប្រតិបត្តិការមហាអនុតំបន់មេគង្គ (GMS) ច្រករបៀងភាគខាងត្បូង (STC) និងតំបន់អភិវឌ្ឍន៍ ត្រីកោណ (CLV-DTA)។
- កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌពិភពលោក និងតំបន់។
- កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន។
- កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ានបូកបី។
- កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន-ឥណ្ឌា។
- កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន-រុស្ស៊ី។
- កិច្ចសហប្រតិបត្តិការទេសចរណ៍ក្នុងក្របខណ្ឌកម្ពុជា-ឡាវ-ភូមា-វៀតណាម (CLMV)។
- កិច្ចសហប្រតិបត្តិការទេសចរណ៍ក្នុងក្របខណ្ឌអេកម៉ិក (ACMECS)។
- កិច្ចសហប្រតិបត្តិការទេសចរណ៍ក្នុងក្របខណ្ឌមេគង្គ-ឡានឆាង (Mekong-Lancang)។
- កិច្ចសហប្រតិបត្តិការទេសចរណ៍ក្នុងក្របខណ្ឌមហាអនុតំបន់មេគង្គ (GMS)។
- កិច្ចសហប្រតិបត្តិការទេសចរណ៍ក្របខណ្ឌទ្វេភាគី។

ពិសេស កម្ពុជាបានរៀបចំដោយជោគជ័យវេទិកាទេសចរណ៍អាស៊ានឆ្នាំ២០២២ ចាប់ពីថ្ងៃទី១៦-២២ ខែមករា ឆ្នាំ ២០២២ នៅខេត្តព្រះសីហនុ ដោយបានប្រកាសបើកទេសចរណ៍អាស៊ានឡើងវិញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

## ៣. លទ្ធផលអនុវត្តគោលដៅយុទ្ធសាស្ត្រទី៣៖ រៀបចំពង្រឹងអភិបាលកិច្ចទេសចរណ៍

### ៣.១. ការរៀបចំពង្រឹងអភិបាលកិច្ចទេសចរណ៍ថ្នាក់ជាតិ

ដើម្បីពង្រឹងយន្តការអភិបាលកិច្ចទេសចរណ៍ឱ្យមានប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលបានសម្រេចបង្កើតយន្តការអន្តរស្ថាប័នមួយចំនួន ដូចជា៖

- ក្រុមការងាររាជរដ្ឋាភិបាល និងឯកជនដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុងក្រោយវិបត្តិជំងឺកូវីដ-១៩ តាមរយៈសេចក្តីសម្រេចលេខ ៨១សសរ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០២១ ដើម្បីអនុវត្តតាមដាន និងវាយតម្លៃផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ។

ទន្ទឹមនឹងនោះ ក្រុមការងារ០៣ផ្សេងទៀតត្រូវបានបង្កើតដើម្បីពង្រឹងការគ្រប់គ្រងគោលដៅទេសចរណ៍សុវត្ថិភាព រួមមាន៖

- ក្រុមការងារប្រតិបត្តិ ដើម្បីវាយតម្លៃ និងគ្រប់គ្រងគោលដៅទេសចរណ៍សុវត្ថិភាពខេត្ត ព្រះសីហនុ ។
- ក្រុមការងារប្រតិបត្តិ ដើម្បីវាយតម្លៃ និងគ្រប់គ្រងគោលដៅទេសចរណ៍សុវត្ថិភាពខេត្ត សៀមរាប។
- ក្រុមការងារប្រតិបត្តិ ដើម្បីវាយតម្លៃ និងគ្រប់គ្រងគោលដៅទេសចរណ៍សុវត្ថិភាពរាជធានីភ្នំពេញ។

- បានបង្កើតគណៈកម្មាធិការដឹកនាំអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ ខេត្តមណ្ឌលគីរី ។
- បានបង្កើតគណៈកម្មការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប-អង្គរ ។
- បានកំពុងបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំអភិវឌ្ឍន៍ផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តក្រចេះ ២០២៣-២០៣៥។
- ក្រោមកិច្ចសហការជាមួយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍(AFD) និងការិយាល័យមេធាវី បាននិងកំពុងរៀបចំក្រមប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់សមាគមឧស្សាហកម្មទេសចរណ៍ និងសម្រាប់សាលាវិជ្ជាជីវៈទេសចរណ៍។
- បានដាក់ឱ្យអនុវត្តប្រើប្រាស់ជាផ្លូវការ ក្រមប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់សាលាវិជ្ជាជីវៈទេសចរណ៍ ។ ដោយឡែកចំពោះក្រមប្រតិបត្តិនិងក្រមប្រតិបត្តិសម្រាប់សមាគមឧស្សាហកម្មទេសចរណ៍ចំនួន០៨ទៀត កំពុងរៀបចំ។
- បានរៀបចំវេទិកាជាតិអេកូទេសចរណ៍លើកទី២កាលពីថ្ងៃទី២៧-២៨ ខែមករា ឆ្នាំ២០២១ ដោយមាន ការចូលរួមពីក្រសួង-ស្ថាប័ន អង្គភាពាក់ព័ន្ធ និងផ្នែកឯកជនចំនួន៤០០នាក់។
- ក្រោមកិច្ចសហការដ៏ល្អរវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងទេសចរណ៍បានប្រកាសប្រើប្រាស់ជាផ្លូវការសៀវភៅទេសចរណ៍មុខវិជ្ជាមួយរៀននៅថ្នាក់ទី ១១ទៅក្នុងកម្មវិធីសិក្សាអប់រំវិជ្ជាជីវៈជម្រើសក្នុងសាលាចំណេះទូទៅ ដើម្បីជាការតម្រង់ទិស និងការទាក់ទាញដល់យុវជន និងសិស្សានុសិស្សឱ្យឃើញពីសារៈសំខាន់នៃវិស័យទេសចរណ៍។

## ៣.២. ការរៀបចំពង្រឹងអភិបាលកិច្ចទេសចរណ៍ថ្នាក់ក្រោមជាតិ

ដើម្បីពង្រឹងយន្តការអភិបាលកិច្ចទេសចរណ៍ឱ្យមានសង្គតភាពរវាងគោលនយោបាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ ដើម្បីដឹកនាំ សម្របសម្រួលនិងអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា ប្រកបដោយនិរន្តរភាព។ ទន្ទឹមនឹងនោះ ក្រសួងទេសចរណ៍ បាននិងកំពុងអនុវត្តនូវសកម្មភាពការងារមួយចំនួន ដូចខាងក្រោម៖

- បានបញ្ចប់ការរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម (២០២១-២០២៥) នៅខេត្តទាំង០៩ នៅភូមិភាគឥសាន្ត និងតំបន់ឆ្នេរ។ ដោយឡែក ខេត្តចំនួន១៥ទៀតកំពុងដាក់ឆ្លងគណៈកម្មាធិការ អភិវឌ្ឍន៍ទេសចរណ៍ខេត្ត និងគ្រោងបញ្ចប់នៅខែមិថុនា ឆ្នាំ២០២២។

- បានបញ្ចប់ការរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម (២០២១-២០២៥) នៅខេត្តទាំង០៩ នៅភូមិភាគឥសាន្តនិងតំបន់ឆ្នេរ។ ដោយឡែក កំពុងបញ្ចប់ការធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍន៍ ទេសចរណ៍នៅខេត្តចំនួន១៥ទៀត។

- បានចុះវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ទេសចរណ៍រាជធានីខេត្ត២០១៨-២០២៣។
- បានចុះជំរុញការធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍន៍រាជធានីខេត្ត២០១៩-២០២៣ ឱ្យទៅជាផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម២០២១-២០២៥ ។

### ៣.៣. លទ្ធផលកម្មវិធីកំណែទម្រង់ការគ្រប់គ្រងរបស់ក្រសួងទេសចរណ៍

ក្រសួងទេសចរណ៍បានរៀបចំកម្មវិធីកែទម្រង់មួយចំនួន ដើម្បីសម្រួលដល់ការធ្វើធុរកិច្ចទេសចរណ៍ និងការគ្រប់គ្រងផ្ទៃក្នុង ដែលបានសម្រេចការងារជាច្រើនរួមមាន៖

- ដាក់បញ្ចូលសេវាកម្មទេសចរណ៍មួយចំនួន រួមមាន សេវាកម្មសណ្ឋាគារ និងស្នាក់នៅទេសចរណ៍, សេវាកម្មភោជនីយដ្ឋាននិងអាហារដ្ឋានទេសចរណ៍ និងសេវាកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ទៅក្នុងថ្នាលបច្ចេកវិទ្យាព័ត៌មាន CamDx។
- កាត់បន្ថយលក្ខខណ្ឌតម្រូវ នៃការស្នើសុំអាជ្ញាបណ្ណទេសចរណ៍ឱ្យមកត្រឹមកម្រិតអប្បបរមា។
- កាត់បន្ថយរយៈពេលនៃការស្នើសុំអាជ្ញាបណ្ណទេសចរណ៍ពី២៨ថ្ងៃ មកត្រឹម៧ថ្ងៃនៃថ្ងៃធ្វើការ។
- ប្រើប្រាស់ប្រព័ន្ធធនាគារទាំងស្រុងសម្រាប់បង់កម្រៃអាជ្ញាបណ្ណទេសចរណ៍។

- ប្រើប្រាស់អាជ្ញាបណ្ណទេសចរណ៍ជាទម្រង់អាជ្ញាបណ្ណអេឡិចត្រូនិចដើម្បីងាយស្រួលដល់ការបោះពុម្ពប្រើប្រាស់ និងកាត់បន្ថយរបាំងមិនចាំបាច់ ដោយរក្សាឱ្យបានភាពប្រកួតប្រជែងខ្ពស់។

### ការងារគ្រប់គ្រងធនធានមនុស្ស

- បច្ចុប្បន្ន មន្ត្រីរាជការសរុបមានចំនួន **១,១៥២នាក់ ស្រី ៤១២នាក់** ក្នុងនោះ៖ ទីស្តីការក្រសួងទេសចរណ៍ មានចំនួន **៦៤២នាក់ ស្រី២២១នាក់** និងមន្ទីរទេសចរណ៍រាជធានីខេត្ត មានចំនួន **៥១០នាក់ ស្រី១៩១នាក់**។
- មន្ត្រីជាប់កិច្ចសន្យាសរុបមានចំនួន**៥៤៥នាក់ ស្រី២៧៧នាក់** ក្នុងនោះទីស្តីការក្រសួងទេសចរណ៍មាន ចំនួន **២៣៧នាក់ ស្រី១១២នាក់** និងមន្ត្រីទេសចរណ៍រាជធានីខេត្តមានចំនួន **៣០៨នាក់ ស្រី ១៦៥នាក់**។
- បានអនុវត្តការបើកប្រាក់ខែជូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធធនាគារ សម្រេចបាន ១០០%និងបើកមួយខែពីរដងនៅរៀងរាល់**សប្តាហ៍ទី២** (៥០%) និង**សប្តាហ៍ទី៤** (៥០%) នៃខែនីមួយៗ។
- បានសហការជាមួយក្រសួងមុខងារសាធារណៈក្នុងការរៀបចំការប្រឡងជ្រើសរើសមន្ត្រីរាជការក្របខណ្ឌថ្មីសម្រាប់ឆ្នាំ២០២១ ចំនួន**១៥នាក់ ស្រី០៥នាក់**។
- បានសហការជាមួយបេឡាជាតិរបបសន្តិសុខសង្គមផ្តល់បណ្ណសមាជិកប.ស.ស ជូនមន្ត្រីកក្រសួង ទេសចរណ៍សរុបចំនួន**១,០២៩នាក់ ស្រី៥១២នាក់** ក្នុងនោះ ឆ្នាំ២០២១ **ចំនួន៤៨៤នាក់ ស្រី ២៤៦នាក់ និងឆ្នាំ២០២២ ចំនួន៥៤៥នាក់ ស្រី២៦៦នាក់**។
- បានសហការជាមួយលេខាធិការដ្ឋាននៃគ.ជ.អ.បធ្វើបច្ចុប្បន្នភាព និងសមាសហរណកម្មរចនាសម្ព័ន្ធ និងធនធានទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងនោះ បានធ្វើសមាហរណកម្មការិយាល័យទេសចរណ៍ក្រុង ស្រុក ខណ្ឌចំនួន១១មន្ទីរ ស្មើនឹង **២៨ការិយាល័យ (០៦ក្រុង, ០៨ស្រុក និង១៤ខណ្ឌ) និងមន្ត្រីចំនួន៣១នាក់ ស្រី០៥នាក់ (មន្ត្រីក្របខណ្ឌ២៧នាក់ ស្រី០៤នាក់ និងមន្ត្រីជាប់ កិច្ចសន្យា០៤នាក់ ស្រី០១នាក់)**។
- បានដាក់ឱ្យអនុវត្តការគ្រប់គ្រងបញ្ជីវត្តមានតាមប្រព័ន្ធតេឡេក្រាម សម្រាប់គ្រប់អង្គភាពនៅទីស្តីការ ក្រសួង និងមន្ទីរទេសចរណ៍រាជធានីខេត្ត។
- បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តនូវរាល់វិធានការនានារបស់រាជរដ្ឋាភិបាល និងបានសហការ ជាមួយក្រសួងសុខាភិបាលរៀបចំកម្មវិធីចាក់វ៉ាក់សាំងកូវីដ-១៩ ជូនមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា មានដូចខាងក្រោម ៖

- **ជួសទី១៖** ចំនួន **៨២០នាក់** ស្មើនឹង **៩៦%** ក្នុងនោះ មន្ត្រីរាជការចំនួន **៦១៣នាក់** ស្មើនឹង **៩៨%** និងមន្ត្រីជាប់កិច្ចសន្យាចំនួន**២០៧នាក់** ស្មើនឹង **៩៨%**
- **ជួសទី២៖** ចំនួន **៨១៦នាក់** ស្មើនឹង **៩៥.៥%**
- **ជួសទី៣៖** ចំនួន **៧៣៨នាក់** ស្មើនឹង **៨៦.៦%**
- **ជួសទី៤៖** ចំនួន **៥៤៨នាក់** ស្មើនឹង**៦៣.៤%** ។

- បានសហការជាមួយក្រសួងមុខងារសាធារណៈក្នុងការផ្តល់ទិន្នន័យថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់ កិច្ចសន្យាដែលចូលរួមបរិច្ចាគប្រាក់បៀវត្សជូនមូលនិធិប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានចំនួន**២២៩នាក់**ស្មើ នឹងទឹកប្រាក់ **៣៧៤,១៤៤,៥០០ រៀល**។

## IV. និសដៅអនុវត្តបន្តឆមាសទី២ ឆ្នាំ២០២២ និងឆ្នាំ២០២៣

សម្រាប់ឆ្នាំ២០២២ និង២០២៣នេះ ក្រសួងទេសចរណ៍នឹងបន្តអនុវត្ត**ផែនការសកម្មភាពដំណាក់កាលទី១ និងចាប់ផ្តើមអនុវត្តសកម្មភាពដំណាក់កាលទី២** ដែលមានចែងក្នុងផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើក ស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ ដូចខាងក្រោម៖

### ១. ការស្តារឡើងវិញឡើងវិញផ្នែកសេដ្ឋកិច្ច និងការងារក្នុងវិស័យទេសចរណ៍

ក្រសួងទេសចរណ៍នឹងសហការជាមួយស្ថាប័នពាក់ព័ន្ធបន្តអនុវត្តកម្មវិធីជំនួយសេដ្ឋកិច្ច និងការងារដូច ខាងក្រោម៖

- បន្តគាំទ្រលើកម្មវិធីគាំពារផ្នែកសេដ្ឋកិច្ច ដូចជា បន្តគាំទ្រហិរញ្ញប្បទានលើកទឹកចិត្តដល់អាជីវកម្ម ទេសចរណ៍ធុនតូច និងមធ្យមក្នុងវិស័យទេសចរណ៍។
- បន្តការពិនិត្យ និងលើកទឹកចិត្តផ្នែកពន្ធដារ និងការលើកទឹកចិត្តនានាដែលបម្រើឱ្យមានការរស់រាននៃ អាជីវកម្មធុនតូច និងមធ្យមក្រោយវិបត្តិជំងឺកូវីដ-១៩។
- បន្តតាមដាន និងវាយតម្លៃផលប៉ះពាល់ និងតម្រូវការផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុមកលើឧស្សាហកម្ម ទេសចរណ៍ និងខ្សែច្រវ៉ាក់តម្លៃក្នុងវិស័យទេសចរណ៍។
- បន្តជំរុញការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារប្បបរមាតាមគន្លងប្រក្រតីភាពថ្មីឱ្យបានគ្រប់សេវាកម្មទេសចរណ៍។
- បន្តជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងឧស្សាហកម្មទេសចរណ៍ ដើម្បីពង្រឹងប្រសិទ្ធភាពនៃ ការគ្រប់គ្រងពង្រីកវិសាលភាពនៃការផ្សព្វផ្សាយ និងបង្កើតផលិតភាពនៃការផ្តល់សេវាកម្ម។

- បន្តរៀបចំកម្មវិធីលើកទឹកចិត្តដល់បុគ្គលដែលមានសមត្ថភាព និងគំនិតច្នៃប្រឌិតក្នុងការស្តារវិស័យ ទេសចរណ៍ឡើងវិញក្រោយវិបត្តិកូវីដ-១៩ ដោយបង្កើតជាយុទ្ធនាការប្រកួតប្រជែងថ្នាក់ជាតិ។
- បន្តកម្មវិធីបណ្តុះបណ្តាលដល់កម្មករ-និយោជិត ដែលបានបាត់បង់ការងារក្នុងវិស័យទេសចរណ៍សម្រាប់ ពង្រឹងជំនាញដែលមានស្រាប់ និងបណ្តុះបណ្តាលជំនាញថ្មី។
- បន្តអនុវត្តយុទ្ធនាការអក្ខរកម្មឌីជីថល និងជំនាញឌីជីថលក្នុងឧស្សាហកម្មទេសចរណ៍ឱ្យបានសកម្ម។
- រៀបចំប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍទេសចរណ៍ឆ្លាតវៃនៅតាមតំបន់គោលដៅទេសចរណ៍សំខាន់ៗ។

## ២. ការស្តារឡើងវិញផ្នែកទីផ្សារទេសចរណ៍អន្តរជាតិ និងបន្តជំរុញទេសចរណ៍ក្នុងស្រុក

- រៀបចំការសិក្សាពីនិន្នាការទីផ្សារទេសចរណ៍ថ្មីៗ និងអាក្បកិរិយាទេសចរណ៍ក្រោយវិបត្តិកូវីដ-១៩។
- បន្តជំរុញការអនុវត្តយុទ្ធនាការ **"កម្ពុជា៖ ជាគោលដៅទេសចរណ៍សុវត្ថិភាព និងបៃតង"** ។
- បន្តសិក្សាគម្រោងលើកទឹកចិត្តជំរុញសកម្មភាពទេសចរណ៍ក្នុងស្រុក ។
- បន្តផ្សព្វផ្សាយ **"កម្ពុជា៖ក្រៅពីប្រាសាទ"** ក្រោម យុទ្ធនាការផ្សព្វផ្សាយទេសចរណ៍ **"កម្ពុជា៖ព្រះរាជាណាចក្រអច្ឆរិយៈ"**។
- បន្តការធ្វើពិពិធកម្មផលិតផលទេសចរណ៍ប្រកបដោយនវានុវត្តន៍ និងច្នៃប្រឌិតទៅតាមតំបន់ប៉ូលទេសចរណ៍សំខាន់ៗ ។
- បន្តការអនុវត្តគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍សម្រាប់កំណើនប្រកបដោយបរិយាបន្នក្នុងមហាអនុតំបន់មេគង្គ និងការត្រៀមសហការបើកដំណើរការកំពង់ផែទេសចរណ៍កំពត ជាច្រកអន្តរជាតិផ្លូវសមុទ្រ។
- បន្តពង្រឹងការរៀបចំ និងកែលម្អមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍រាជធានីខេត្ត តាមរយៈយន្តការ ប្រឡងប្រណាំងមជ្ឈមណ្ឌលព័ត៌មានឆ្នើម។
- បន្តអនុវត្តវិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុងឆ្នាំ២០២១-២០២៣ និងផែនការ យុទ្ធសាស្ត្រស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង។
- បន្តសម្របសម្រួលជាមួយភាគីពាក់ព័ន្ធក្នុងការសម្រួលធ្វើដំណើរតាមផ្លូវអាកាស ។
- រៀបចំយុទ្ធសាស្ត្រទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍ទៅកាន់ទីផ្សារទេសចរណ៍សំខាន់ៗតាមប្រព័ន្ធឌីជី ថល (E-Marketing)។

- បន្តជំរុញចលនាឱ្យមានការរៀបចំប្រជុំនិងសន្និសីទនានា របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ នៅតាមបណ្តា រាជធានីខេត្ត ពិសេស ការរៀបចំព្រឹត្តការណ៍ទេសចរណ៍សខាន់ៗឱ្យកាន់តែមានភាពទាក់ទាញ និងច្នៃប្រឌិត។
- រៀបចំផែនការផ្សព្វផ្សាយ **"កម្ពុជាៈ ជាគោលដៅទេសចរណ៍កីឡា"** ឆ្ពោះទៅកាន់ព្រឹត្តការណ៍ SEA Game 2023។

## ៣. ការពង្រឹងអភិបាលកិច្ចទេសចរណ៍

- បន្តអនុវត្តផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា(២០២១-២០៣៥)។
- បន្តអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តសៀមរាប(២០២១-២០៣៥), ផែនការមេអភិ វឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគីរី(២០២១-២០៣៥) និងផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ ខេត្តកែប (២០២២-២០៣៥)។
- បន្តសិក្សារៀបចំផែនការមេ ដើម្បីអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តក្រចេះ ឆ្នាំ២០២៣-២០៣៥។
- បន្តរៀបចំគោលនយោបាយស្តីពីទេសចរណ៍ពិសេស រួមទាំងគោលនយោបាយពាក់ព័ន្ធមួយចំនួនទៀត ។
- យន្តការកសាងសាលាជាតិវិជ្ជាជីវៈទេសចរណ៍នៅភ្នំពេញ ខេត្តព្រះសីហនុ និងខេត្តសៀមរាប ។
- បន្តពង្រឹងភាពជាដៃគូរវាងរដ្ឋ-ឯកជនតាមយន្តការ (PPP) ក្នុងការពង្រឹងរចនាសម្ព័ន្ធនៃការឆ្លើយតប អភិវឌ្ឍន៍ និងផ្សព្វផ្សាយទេសចរណ៍។
- បន្តពង្រឹងសមត្ថភាពគ្រប់គ្រងនៃគណៈកម្មការគ្រប់គ្រងអភិវឌ្ឍន៍ទេសចរណ៍រាជធានីខេត្ត។
- បន្តជំរុញការរៀបចំបង្កើតអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តាមរាជធានីខេត្ត និងគោលដៅ ទេសចរណ៍សំខាន់ៗ ដោយផ្តល់អាទិភាពលើការរៀបចំអង្គភាពគ្រប់គ្រងគោលដៅខេត្តសៀមរាប, ខេត្តមណ្ឌលគីរី និងខេត្តកែប។
- បន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងក្របខណ្ឌពិភពលោក និងតំបន់ពិសេសកិច្ចសហការ ទ្វេភាគី និងពហុភាគី។
- បន្តរៀបចំកិច្ចការងារកំណែទម្រង់ការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួងទេសចរណ៍ ទាំងការគ្រប់គ្រងរដ្ឋបាល, ហិរញ្ញវត្ថុ, ធនធានមនុស្ស និងសវនកម្មផ្ទៃក្នុងឱ្យមានភាពទំនើបកម្មស្របតាមការវិវត្តន៍នៃឧស្សាហកម្មទេសចរណ៍ក្នុងយុគ្គសម័យ៤.០។
- រៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការតាមបែបឌីជីថលឆ្នាំ២០២២-២០២៦។

- បន្តពង្រឹងយន្តការគណៈកម្មាធិការគណៈកម្មការ និងក្រុមការងារនានាចំណុះក្រសួងទេសចរណ៍។

## V. សេចក្តីសន្និដ្ឋាន

វិបត្តិនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងខ្លាំងមិនធ្លាប់មានក្នុងរយៈពេល៣០ឆ្នាំចុងក្រោយលើការអភិវឌ្ឍន៍ វិស័យទេសចរណ៍កម្ពុជា។ ទោះជាយ៉ាងណាក្តីជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធ ប្រឆាំងជំងឺកូវីដ-១៩ ក្នុងស្មារតីបុរេសកម្ម និងហ្មត់ចត់តាមរយៈការដាក់ចេញជាបន្តបន្ទាប់នូវវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការច្បាប់កម្ពុជាពិតជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងស្ថានភាពនៃ ការរីករាលដាលជំងឺកូវីដ-១៩បានល្អប្រសើរ គួបផ្សំនឹងការដាក់ចេញនូវគោលនយោបាយជំនួយសេដ្ឋកិច្ច-សង្គម ទាន់ពេលវេលា រួមមាន គោលនយោបាយលើកលែងពន្ធអាករ, ការលើកលែង កម្រៃអាជ្ញាបណ្ណទេសចរណ៍ និងកម្មវិធីជំនួយសាច់ប្រាក់ដល់ជនក្រីក្រ ។ ពិតជាធ្វើឱ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍មួយប្រកបដោយ**សុវត្ថិភាព និងបៃតង**ក្នុងតំបន់ និងសាកលលោក ដែលធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមួយក្នុងតំបន់ដែល បានមានលក្ខខណ្ឌធ្វើដំណើរចេញ-ចូលប្រទេសមានភាពងាយស្រួល និងធានាបាននូវសុវត្ថិភាពជូនទេសចរជាតិ និងអន្តរជាតិ។ វិស័យទេសចរណ៍កម្ពុជាមានចក្ខុវិស័យប្រកបដោយសុទិដ្ឋិនិយម ថានឹងអាចវិលទៅរកសភាពប្រហាក់ប្រហែលនឹងស្ថានភាពទេសចរណ៍ឆ្នាំ២០១៩វិញ នៅក្នុង**ឆ្នាំ២០២៦** ប៉ុន្តែទោះជាយ៉ាងនេះក្តីសម្ពាធពីកត្តាខាងក្រៅមួយចំនួន ដូចជា ចរន្តនៃការធ្វើដំណើរទេសចរចេញក្រៅ (Outbound) សំខាន់ៗ, លទ្ធភាពនៅក្នុងការផ្លាស់ប្តូរ **"គោលនយោបាយគ្មានកូវីដ-១៩"** (Zero-COVID Policy) របស់ប្រទេសចិន នៅក្នុងពេលខាងមុខ, ឥទ្ធិពលនៃវិបត្តិនៅអ៊ុយក្រែន, ឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចដែលបានធ្វើឱ្យមានការថមថយ អំណាចទិញនិងបានជំរុញឱ្យមានការផ្លាស់ប្តូរគោលដៅនៃការតភ្ជាប់មកកាន់កម្ពុជាទាំងតាមផ្លូវអាកាស ផ្លូវគោក និងផ្លូវទឹក, ការប្រកួតប្រជែងស្រួចស្រាលពីប្រទេសជិតខាងដែលជាគោលដៅទាក់ទាញទេសចរពីប្រភពទីផ្សារ ដូចគ្នា និងការផ្លាស់ប្តូរឥរិយាបទនៃការធ្វើដំណើររបស់ទេសចរជាសកល អាចនឹងធ្វើឱ្យចក្ខុវិស័យទេសចរណ៍ ប្រែប្រួលដែលអាចឈាន ដល់ការពន្យាពេលនៃការងើបឡើងវិញមកស្ថានភាពប្រហាក់ប្រហែលឆ្នាំ២០១៩ ដល់**ឆ្នាំ២០២៦ ឬ២០២៧**។

ស្ថិតក្នុងបរិការណ៍នៃភាពមិនច្បាស់លាស់នេះ ការចូលរួមមិនអាចខ្វះបានរបស់គ្រប់ភាគីពាក់ព័ន្ធដោយ ឈរលើគោលការណ៍ចតុភាគី **"រដ្ឋ-ឯកជន-ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ-ដៃគូនៅក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី"** នឹងក្លាយជាចលករក្នុងការជំរុញវិស័យទេសចរណ៍កម្ពុជា

ឱ្យវិលមករកភាពដើមវិញ ស្របតាមចក្ខុ វិស័យដែលបានចែងក្នុងផែន**ទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុងនិងក្រោយ វិបត្តិជំងឺកូវីដ-១៩** ។ ក្រសួងទេសចរណ៍ក្រោមកិច្ចសហការរបស់ស្ថាប័ន អង្គភាព ផ្នែកឯកជន និងភាគីពាក់ព័ន្ធបានចូលរួម និងអនុវត្តសម្រេចផែនការសកម្មភាពលម្អិតដែលមានចែងក្នុងផែនទី ចង្អុលផ្លូវស្តីពីផែនការស្តារ និង លើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ ដំណាក់កាលទី១ បានប្រមាណជិត**៧០ភាគរយ** និងកំពុងបន្តអនុវត្តបញ្ចប់ផែនការដំណាក់កាលទី១និងបន្តអនុវត្តផែនការដំណាក់កាលទី២ ឱ្យមានប្រសិទ្ធិភាពខ្ពស់ និងឈានទៅស្រោចស្រង់វិស័យទេសចរណ៍កម្ពុជាឱ្យវិលមករក សភាពដើមវិញឱ្យបានឆាប់បំផុត និងកាន់តែរីកចំរើនថែមទៀត ដើម្បីចូលរួមដល់សេដ្ឋកិច្ចជាតិ បង្កើតការងារ និងតម្លៃបន្ថែមជូនជាតិ និងប្រជាពលរដ្ឋគ្រប់រូប៕

**សូមគោរពជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ព្រមទាំងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ៕**